# ការក្តោបក្តាប់ប្រព័ន្ធស្បៀង ពីក្រុមហ៊ុនសាជីវកម្ម



អំណាចគ្រប់ដណ្តប់ទៅលើប្រព័ន្ធស្បៀង ពីគ្រាប់ពូជ ដល់អាហារ
លើចានត្រូវបានបន្តស្ថិតក្នុងដៃរបស់ក្រុមហ៊ុនសាជីវកម្ម
តែពីរបីប៉ុណ្ណោះ។

# កសិកម្ម
# ខ្នាតធំ

ក្រុមហ៊ុនត្រឹមតែបួនប៉ុណ្ណោះដូចជា៖ ក្រុមហ៊ុនបេយើ-Bayer, ក្រុមហ៊ុនស៊ីហ្សែនតាគ្រុប-Syngenta Group, ក្រុមហ៊ុនកសិកម្មខទេវ៉ា-Corteva និងក្រុមហ៊ុនប៊ីអេអេសហ្វេស-BASF

- គ្រប់គ្រងប្រមាណពីរភាគបីនៃទីផ្សារឧស្សាហកម្មលើគ្រាប់ពូជ និងថ្នាំសម្លាប់សត្វល្អិត។ ពួកគេបានគ្រប់គ្រងទៅលើអ្វីដែលកសិករដាំដុះ និងរបៀបដែលពួកគេដាំដុះ។ ស្ថានភាពស្រដៀងគ្នានេះត្រូវបានរកឃើញ នៅក្នុងឧស្សាហកម្មហ្សែនសត្វ។



# ហិរញ្ញវត្ថុ ខ្នាតធំ

វិស័យហិរញ្ញវត្ថុដូចជាក្រុមហ៊ុនវិនិយោគ និងធនាគារអភិវឌ្ឍន៍ បានក្លាយជាតួអង្គដ៏សំខាន់នៅក្នុងប្រព័ន្ធអាហារឧស្សាហកម្ម ដែលជារឿយៗ ពួកគេជាអ្នក"ទាញខ្សែ" នៅពីក្រោយរឿងរ៉ាវដែលកើតឡើង។ ដីធ្លី និងអាហារត្រូវបានបន្តកើនឡើងចាត់ទុកជាទ្រព្យសម្បត្តិហិរញ្ញវត្ថុ និងជាទំនិញដែលអាចដោះដូរបាន។ បណ្តាញវិនិយោគដែលមិនមានភាពច្បាស់លាស់ធ្វើឱ្យមានផលលំបាកក្នុងការតាមដានលំហូរហិរញ្ញវត្ថុ និងវិស័យវិនិយោគ ព្រមទាំងមានការធានានូវគណនេយ្យភាពចំពោះប្រតិបត្តិការហិរញ្ញវត្ថុ ដែលបណ្តាលឱ្យមានការរំលោភសិទ្ធិមនុស្ស។



ក្រុមហ៊ុនបច្ចេកវិទ្យាដូចជា ម៉ាយក្រូសហ្វ អាម៉ាហ្សូន ឬ អាលីបាបា កំពុងបង្កើនការចូលរួមរបស់ពួកគេកាន់តែខ្លាំងក្នុងការវិនិយោគទៅលើអាជីវកម្មស្បៀងអាហារ និងកសិ-ពាណិជ្ជកម្មក្នុងការទាញយកទិន្នន័យពីប្រព័ន្ធអាហារ និងការអភិវឌ្ឍលើប្រព័ន្ធបច្ចេកវិទ្យា។ ឌីជីថលភាវូបនីយកម្មនៃប្រព័ន្ធស្បៀងអាហារបានបង្កើនល្បឿនរបស់ខ្លួនដោយក្រុមហ៊ុនសាជីវកម្មចង់ "ប្រមូល" ទិន្នន័យឱ្យបានច្រើនយ៉ាងឆាប់រហ័សពី"ខ្សែសង្វាក់ស្បៀងអាហារ" ដើម្បីទទួលបានអត្ថប្រយោជន៍ពីទីផ្សារក្នុងការឈ្នះដៃគូរប្រកួត។

# បច្ចេកវិទ្យាខ្នាតធំ






# ស្បៀងអាហារ ខ្នាតធំ

សាជីវកម្មមួយចំនួនតូចដែលគ្រប់គ្រងផលិតកម្ម ឧស្សាហកម្ម និងការលក់ស្បៀងអាហារ ភេសជ្ជៈ ហើយបានបន្តបង្កើននូវឥទ្ធិពលរបស់ពួកគេទៅលើការកំណត់នូវអ្វីដែលយើងហូប។


.... ហើយធ្វើការផ្លាស់ប្តូរ
ដៃគូរបស់អ្នក
ការផ្តោតរបស់សាជីវកម្ម គឺលែង
ត្រឹមតែទៅលើភាពស្របគ្នាទៀត
( ក្នុងវិស័យដែលមានស្រាប់នោះទេ )
ប៉ុន្តែមានការកើនឡើង
( នៅតាមខ្សែសង្វាក់អាហារ )។
GMO
ពូជបង្កាត់
ថ្នាំសម្លាប់សត្វល្អិត


ខ្ញុំស្អប់ដែលត្រូវធ្វើខ្លួនជាព្រះ,
ប៉ុន្តែ...តោះលេងល្បែងនេះ!
វាមិនល្អទេ
ខ្ញុំត្រូវការកន្លែងទំនេរបន្ថែម។
បទប្បញ្ញត្តិបន្ថែមស្អីគេ?
សូមបញ្ចុះសពពួកគេ
នៅទីនេះ។
គ្មានតម្លៃតិចតួចអ្វី
ដែលវិស្វកម្មនឹង
មិនធ្វើនោះទេ។
ពូជបង្កាត់
GMO
ថ្នាំសម្លាប់សត្វល្អិត

# ការគ្រប់គ្រងលើប្រព័ន្ធស្បៀងអាហារ ពីសំណាក់ក្រុមហ៊ុនសាជីវកម្ម - ការឧបត្ថម្ភពីរដ្ឋត្រូវបានបំផ្លាញរួមទាំងសិទ្ធិមនុស្ស ចំពោះការទទួលបានស្បៀងអាហារនិងអាហារូបត្ថម្ភតាមវិធីសាស្ត្រជាច្រើន ហើយនិងជាមូលហេតុមួយនៃការនាំឱ្យមានភាពអត់ឃ្លាននិងកង្វះអាហារូបត្ថម្ភ។

ប្រព័ន្ធស្បៀងឧស្សាហកម្មពឹងផ្អែកលើការកេងប្រវ័ញ្ចមនុស្ស និងធម្មជាតិ។ វាអនុញ្ញាតឱ្យការផលិតមានតម្លៃទាប និងបង្កើនប្រាក់ចំណេញកសិកម្មបែបឧស្សាហកម្ម។ ផ្អែកលើគ្រាប់ពូជតែមួយមុខ ធាតុចូលគីមី និងគ្រាប់ពូជពាណិជ្ជកម្ម ដែលវាជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធនេះហើយ វាមានឥទ្ធិពលទៅលើនយោបាយដែលក្រុមហ៊ុនសាជីវកម្មមាន។

បច្ចេកវិជ្ជាខ្ពស់កាត់បន្ថយតួនាទីរបស់កសិករ និងកម្មករមកត្រឹមជាអ្នកប្រតិបត្តិ។ បើពុំដូច្នេះទេគឺធ្វើឱ្យពួកគេលែងមានតួនាទីទាំងស្រុង។ វាក៏បង្កើតឱ្យមានភាពពឹងផ្អែកទៅលើម្ចាស់បច្ចេកវិទ្យាទាំងនេះ ដែលជារឿយៗផ្សារភ្ជាប់ជាមួយនឹងបំណុល។




អ្នកអាច ចាកចេញឥឡូវនេះ។ យើងទទួលបានលេក្ខជន របស់យើងហើយ។
ចម្លង
ប្រភេទនៃគ្រាប់ពូជ
កសិឧស្សាហកម្មជាកត្តាចម្បងមួយ ដែលជំរុញឱ្យបាត់បង់នូវជីវចម្រុះជាច្រើន។ ក្នុងចំណោមប្រភេទរុក្ខជាតិជាង៦០០០ប្រភេទ ដែលត្រូវប្រមូលផលនៅទូទាំងពិភពលោកសម្រាប់អាហារ (ដោយមិនរាប់បញ្ចូលពូជព្រៃរាប់លាន ដែលត្រូវបានទុកចោល)មានត្រឹមតែ៩នៃពូជនេះ ដែលមានសម្រាប់២ភាគ៣ នៃផលិតកម្មដំណាំពិភពលោក។ ពូជក្នុងស្រុកជាច្រើនប្រភេទត្រូវបានបាត់បង់ ឬក្លាយជាពូជកម្រដោយសារបញ្ហាខាងលើនេះ។

# ប្រព័ន្ធស្បៀងអាហារឧស្សាហកម្ម បានដើរតួនាទីជាស្នូល ក្នុងការបំផ្លាញប្រព័ន្ធអេកូឡូស៊ី និងជាផ្នែកដ៏ចម្បងមួយ ក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបម្រែបម្រួលអាកាសធាតុ។

ការកាប់បំផ្លាញព្រៃឈើ ការប្រើប្រាស់ខ្ជះខ្ជាយ និងការបំផ្លាញធនធានធម្មជាតិ និងការបំពុលប្រភពទឹកដី និងខ្យល់គឺជាបញ្ហាបន្ថែមទៀត។ ភាពប្រញាប់ប្រញាល់របស់ក្រុមហ៊ុនសាជីវកម្ម ក្នុងការយកដីមកផលិតបង្កើនផល ព្រមទាំងធនធានហិរញ្ញវត្ថុ បានបណ្តាលឱ្យមានការទន្ទ្រានដកហូតដីធ្លី ទឹក យ៉ាងគំហុក ហើយនេះមានន័យថា ប្រជាពលរដ្ឋដែលរស់នៅនិងពឹងផ្អែកទៅលើធនធានទាំងអស់សម្រាប់ឆ្លើយតប ទៅនឹងសិទ្ធិទទួលបានស្បៀងអាហារ និងអាហាររូបត្ថម្ភទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។




ព្រៃឈើប្រមាណ ៤២០លានហិកតា ត្រូវបានបាត់បង់ ដោយសារតែការ កាប់បំផ្លាញព្រៃឈើ តាំងពីឆ្នាំ ១៩៩០។
អេ ត្រង់នោះ ធ្លាប់ជាផ្ទះ របស់យើង...
សូមទោស អ្នកមិនអាចរារាំង ផ្លូវនៃការរីកចម្រើន បានទេ!
បំបែក
បែកប្រេះ

កម្មករដែលធ្វើការក្នុងខ្សែសង្វាក់ស្បៀងអាហារ ជារឿយៗទទួលរងនូវ
លក្ខខណ្ឌការងារអាក្រក់ រួមទាំងភាពងាយរងគ្រោះធ្ងន់ធ្ងរពីសារធាតុគីមី
ដែលផ្តល់ផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាព  និងសុខុមាលភាពរបស់ពួកគេ។
ពួកគេពឹងផ្អែកទៅលើប្រាក់ឈ្នួលដែលមិនអាចចិញ្ចឹមជីវិតគ្រប់គ្រាន់
សេវាសង្គមដែលមិនមានគុណភាព ប្រឈមនឹងការរើសអើង
និងការកេងប្រវ័ញ្ចផ្លូវភេទ និងទម្រង់នានា ស្របពេលដែលពួកគេអង្កេតឃើញថា
សិទ្ធិនយោបាយរបស់ខ្លួនត្រូវបានគាបសង្កត់។


តើពណ៌ខៀវនេះជាអ្វី?
វាជាថ្នាំសម្រាប់រុក្ខជាតិ។ វាត្រូវតែល្អសម្រាប់ពួកយើងដែរ!

អ្នកផលិតស្បៀងអាហារខ្នាតតូច និងបណ្ដាញអ្នកស្រែត្រូវបានច្របាច់ "បញ្ចូល"
ទៅក្នុងប្រព័ន្ធស្បៀងអាហាររបស់ក្រុមហ៊ុនសាជីវកម្ម និងដោយច្បាប់ពាណិជ្ជកម្មនានា។
បញ្ហាទាំងនេះរួមមានការបាត់បង់ការគ្រប់គ្រងទៅលើអ្វី ដែលពួកគេចង់ផលិតព្រមទាំងរបៀបក្នុងការផលិត
បញ្ហាគំនាបទៅលើតម្លៃកសិផលរបស់ពួកគេ ការពឹងផ្អែកលើធាតុចូលកសិកម្មពាណិជ្ជកម្ម និងបំណុល
ការទន្ទ្រាននិងដកហូតយកដីធ្លី ព្រមទាំងការធ្វើឯកជនភាវូបនីយកម្មទៅលើធនធាន
សមូហភាពរបស់សហគមន៍ និងការបំពុលធនធានទាំងនេះដែលពួកគេពឹងផ្អែកទៅលើ។




BIG BOY
ផ្សារអាហារ
បិទ
WROOOOOMM
សួនច្បារតូច
គួរឱ្យស្រឡាញ់
ដែលអ្នកមាននៅទីនេះ។
WROOOOOMM
ទឹកស្អាត
របស់យើង
ក្រឹកៗ...
ក្រឹកៗ...
ZZZZZZZZZZ
BBBRRRRRRRRRRRR

ការធ្វើទីផ្សារយ៉ាងខ្លាំងទៅលើប្រភេទអាហារកែច្នៃ
("អាហារគ្មានប្រយោជន៍") ជាពិសេសជាមួយកុមារ មនុស្សវ័យជំទង់
ព្រមទាំងការប្រមូលផ្ដុំយកទីផ្សារពីកសិករ និងអាជីវករខ្នាតតូច
ពីសំណាក់បណ្ដាញខ្សែសង្វាក់លក់រាយ ដោយក្រុមហ៊ុនសាជីវកម្មផ្ដល់ផលប៉ះពាល់ដល់
វប្បធម៌នៃការទទួលទានរបបអាហារ និងសុខភាពរបស់មនុស្សផងដែរ។

ភាពលើសទម្ងន់នៅទូទាំងពិភពលោក បានកើនឡើងបីដងចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ទី៧០ ខណៈពេលដែលមនុស្សពេញវ័យច្រើនជាង១នាក់ក្នុងចំណោម៣នាក់បច្ចុប្បន្នលើសទម្ងន់។ បញ្ហាការលើសទម្ងន់ និងជាពិសេសជំងឺធាត់នេះ គឺជាកត្តាហានិភ័យដ៏ចម្បងនៃជំងឺមិនឆ្លង ដូចជាជម្ងឺគាំងបេះដូង និងជម្ងឺទឹកនោមផ្អែម។ អ្នកជម្ងឺនេះមានភាពប្រឈមខ្ពស់ទៅនឹងការឆ្លងជម្ងឺដូចជាកូវីដ-១៩ជាដើម។



# ការផ្សព្វផ្សាយពីអាហារកែច្នៃវេចខ្ចប់បាន ជំរុញឱ្យមានរបបអាហារតែមួយប្រភេទ ដូចនេះហើយវា បានបំផ្លាញវប្បធម៌និងចំណេះដឹងរបស់សហគមន៍ ទៅលើស្បៀងអាហារ និងអាហារូបត្ថម្ភ។

ការអនុវត្តនានាចំពោះការចម្អិនម្ហូបអាហារ ដែលលើកកម្ពស់អាហាររូបត្ថម្ភ និងសុខភាពល្អដោយផ្តោតទៅលើធនធាន និងបរិបទមូលដ្ឋានព្រមទាំងពូជដំណាំជាច្រើន ត្រូវបានជំនួសដោយរបបអាហារដែលដូចគ្នាហើយផ្អែកលើពូជដំណាំមួយចំនួនតូច។ ទំនុកចិត្តរបស់សហគមន៍ អំពីរបៀបចិញ្ចឹមកូនឱ្យទទួលបានអាហាររូបត្ថម្ភល្អបំផុតតាមរយៈការប្រើប្រាស់អាហារស្រស់ៗ និងអាហារចម្រុះពីមូលដ្ឋានដោយទឹកដោះម្តាយត្រូវបានបំផ្លាញ។




មានសារធាតុចិញ្ចឹម
ទាំងអស់ដែលកូនអ្នកត្រូវការ
ដើម្បីរីកលូតលាស់រឹងមាំ
និងមានសុខភាពល្អ!
អនាម័យ !!!
ពិតៗ
ថាមពល
អាហារ-សម្រាប់-ថ្ងៃនេះ
ខ្លាញ់
អស្ចារ្យ
អាហារទារក
កូកា-កូឡា
បារថាមពល
រសជាតិផ្លែស្វាយ
ភីហ្សា
កន្លែងរក្សាទុក
ទំនិញ
ល្អៗ
សណ្ដែកសៀង
FDA បានអនុម័ត
?
អស្ចារ្យ !
គ្រួសារខ្ញុំប្រាប់ថា
បើសិនម្ហូបណាមួយមិនត្រូវបាន
ទទួលស្គាល់ដោយលោកយាយ
របស់ខ្ញុំថាជាអាហារទេ វាប្រាកដ
ជាមិនមែនទេ។

សាជីវកម្មចំណាយរាប់ពាន់លានដើម្បី
ធ្វើឱ្យពួកគេនឹងផលិតផលរបស់
ពួកគេមើលទៅល្អ និងទាក់ទាញ។




បន្ថែមពីការធ្វើទីផ្សារតាមបែបប្រពៃណីនៃផលិតផលរបស់ពួកគេ
ពួកគេបង្កើនការផ្តល់មូលនិធិដល់ប្រព័ន្ធផ្សព្វផ្សាយធំៗ និងការស្រាវជ្រាវក្នុងគោលបំណងមានឥទ្ធិពលទៅលើមតិសាធារណៈ
បង្ហាញពីវិធីសាស្ត្រចំពោះបញ្ហាដែលសមស្រប និងរៀបចំទិន្នន័យ
ជាឧទាហរណ៍ គេចង់បង្ហាញថាអាហារកែច្នៃមិនមានគ្រោះថ្នាក់ប៉ះពាល់ដល់សុខភាពទេ។

នៅពេលដែលមានការអំពាវនាវឱ្យមានការផ្លាស់ប្តូរដាច់ខាតនូវ
ប្រព័ន្ធស្បៀងអាហារដោយឆ្ពោះទៅរកការអនុវត្ត ដែលមានសុខភាពល្អ
យុត្តិធម៌ និងនិរន្តរភាពកាន់តែខ្លាំងឡើង ក្រុមហ៊ុនសាជីវកម្មកំពុងស្វែងរកវិធីថ្មី
ដើម្បីឱ្យពួកគេមានឥទ្ធិពល ទៅលើគោលនយោបាយសាធារណៈដើម្បីការពារ
ផលប្រយោជន៍របស់ខ្លួន។



សាជីវកម្មបានលើកឡើងដោយជោគជ័យថា ពួកគេត្រូវតែទទួលបានកៅអីមួយនៅក្នុងតុប្រជុំនិងជា"ផ្នែកនៃដំណោះស្រាយ"។ គំនិតផ្តួចផ្តើមដែលមានឈ្មោះថា "អ្នកពាក់ព័ន្ធពហុភាគី" ដែលត្រូវបានលើកកម្ពស់យ៉ាងខ្លាំងពីសប្បុរសជនដូចជាមូលនិធិលោក **បៀល និងមីលីនដាហ្គេត** កំពុងក្លាយជាការជម្រុញ ដ៏សំខាន់ពីសាជីវកម្មដើម្បីឱ្យពួកគេមានឥទ្ធិពលទៅលើការសម្រេចចិត្តជាសាធារណៈ។




គ្រប់គ្រងបរិស្ថាន
លទ្ធិប្រជាធិបតេយ្យ
សមភាព
សិទ្ធិមនុស្ស
គណនេយ្យភាព
ដំណោះស្រាយតាមបែបបច្ចេកវិទ្យា
កំណើនសេដ្ឋកិច្ច
ភាពងាយស្រួលសម្រាប់វិនិយោគ
តុល្យភាពអំណាច
ខ្ពស់
ពាក់កណ្ដាល
ទាប
មិនដែលប្រើប្រាស់

ការចូលរួមក្នុងវេទិកាធ្វើគោលនយោបាយសាធារណៈទាំងដោយផ្ទាល់ ឬតាមរយៈក្រុមផ្ទរមុខ
ដែលគាំទ្រដោយសប្បុរសជន និងរដ្ឋាភិបាលដែលជាសម្ព័ន្ធមិត្តជាមួយគ្នាបានអនុញ្ញាតឱ្យពួកក្រុមហ៊ុនសាជីវកម្ម
រួចផុតពីការទទួលខុសត្រូវជុំវិញបញ្ហាដើមចមនៃភាពអត់ឃ្លាននឹងកង្វះអាហាររូបត្ថម្ភ និងរារាំងការអនុវត្តវិធានការនានា
ដែលអាចកាត់បន្ថយអំណាច និងផលប្រយោជន៍របស់ពួកគេ។

វាបានជួយបង្វែរកិច្ចពិភាក្សាទៅលើ “ការដោះស្រាយបញ្ហាដោយបច្ចេកវិទ្យា”
ជំនួសវិញហើយ ដែលដំណោះស្រាយនេះគឺផ្អែកទាំងស្រុងទៅលើប្រព័ន្ធស្បៀងឧស្សាហកម្ម
ព្រមទាំងពង្រីកនូវអំណាចរបស់ក្រុមហ៊ុនសាជីវកម្មឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត និងធ្វើឱ្យអ្នកផលិតខ្នាតតូច
និងសហគមន៍នានាបន្តរងគ្រោះកាន់តែខ្លាំងឡើង។

ការផលិតដំណាំនានាធ្វើឱ្យគុណភាពអាហាររូបត្ថម្ភកាន់តែប្រសើរឡើង
តាមរយៈការពង្រឹងជីវសាស្ត្រ(រួមទាំងការកែប្រែហ្សែន)
ត្រូវបានជម្រុញយ៉ាងខ្លាំង វាជាដំណោះស្រាយកង្វះខាត
សារធាតុចិញ្ចឹមតូចៗ។





ការមិនអើពើចំពោះហានិភ័យនានាដែលពាក់ព័ន្ធ
ជាពិសេស នៅពេលដែលបច្ចេកវិទ្យាជីវសាស្ត្រត្រូវបាន
ប្រើប្រាស់។ វាបង្កើតការពឹងផ្អែកទៅលើបច្ចេកវិទ្យាទាំងនេះ
ពីសំណាក់កសិករ ដូចជាគ្រាប់ពូជបង្កាត់ដែលបណ្ដាលឱ្យ
បាត់បង់ជីវចម្រុះ និងរបបអាហារស្របពេលលទ្ធផល
នៃដំណោះស្រាយស្ថិតនូវជាមន្ទិលនៅឡើយ។


ការរស់រានមានជីវិតនៅតំបន់អាក់ទិក
បាង!
បាង!
RRRRRR
RR
SSSSSSSSS
ហ្វ្រីង ដុង!
RRR
វីតាមីន +
អាហារបំប៉ន
ការពង្រឹងជីវសាស្ត្រ ត្រូវបានលើកកម្ពស់យ៉ាងខ្លាំងនៅក្នុងបណ្ដាប្រទេសជាម្ចាស់ផ្ទះ ដែលមានភាពដ៏សម្បូរបែបនៃដំណាំអាហារដែលមានជីវជាតិធម្មជាតិ។
កាំរស្មីព្រះអាទិត្យ


មូលហេតុ ឬសគល់នៃកង្វះអាហារូបត្ថម្ភនៅកន្លែងទាំងនេះ
កម្រទាក់ទងទៅនឹងកង្វះខាតអាហារូបត្ថម្ភ ប៉ុន្តែផ្ទុយទៅវិញត្រូវបានចោទសួរ
ពីការទទួលបានអាហារទៅវិញ។
PLOP
SSSSSSSSS
SSSSSSS


អ្នកដឹងទេ, ខ្ញុំច្រូតគ្រាប់ពូជ,
កប់វានៅក្នុងដីហើយ ...
វាក៏ដុះរីកលូតលាស់!

កសិកម្មឆ្លាតវៃតាមអាកាសធាតុ និងដំណោះស្រាយផ្អែកលើធម្មជាតិ
គឺជាពាក្យដែលនិយមចូលចិត្តនិយាយតៗគ្នា ដែលជារឿយៗពាក្យនេះ
ត្រូវបានយកមកប្រើប្រាស់ហាក់ដូចជាការអនុវត្តប្រកបដោយនិរន្តរភាព
ប៉ុន្តែ នៅពេលមើលឱ្យកាន់តែស៊ីជម្រៅ បង្ហាញពីផលប៉ះពាល់អវិជ្ជមាន
ដូចគ្នានៃផលិតកម្ម។


នេះគួរ
តែ
ជួសជុលវា

ជំនួបកំពូលរបស់អង្គការសហប្រជាជាតិ ស្តីពីប្រព័ន្ធស្បៀងអាហារពិភពលោកជាលំហរមួយដែលក្រុមហ៊ុនសាជីវកម្មទទួលបានឱកាសអង្គុយក្នុងកន្លែងដែលពួកគេអាចដាក់បញ្ចូលដំណោះស្រាយពីពួកគេលើតុ។






ទោះជាយ៉ាងណាក៏ដោយការតស៊ូប្រឆាំងនឹងប្រព័ន្ធស្បៀងអាហារសាជីវកម្ម
និងដំណោះស្រាយក្លែងក្លាយ ដែលស្នើឡើងចំពោះបញ្ហាដែលវាបានបង្កឡើង កំពុងតែកើនឡើង។

ដំណោះស្រាយពិតប្រាកដ
ដែលសហគមន៍ជុំវិញពិភពលោក
បានអនុវត្តរួចហើយ មិនអាចមិនអើពើបានទៀតទេ!





កសិត្របរិស្ថាន ឥឡូវនេះ!
ពួកយើងមើលថែ មាតាធម្មជាតិ ហើយនាងក៏មើលថែ យើងវិញដែរ។
ត្រូវការពារ និងលើក កម្ពស់វប្បធម៌ ចំណេះដឹង រួមគ្នា
អធិបតេយ្យភាព ស្បៀង ឥឡូវនេះ!
ចែករំលែក ការងារថែរក្សា ឡើងវិញ!
ដាក់ប្រជាជន នៅកណ្តាល មិនមែន សាជីវកម្ម!
អភិបាលកិច្ចផ្អែក លើសិទ្ធិមនុស្ស ប្រព័ន្ធស្បៀងអាហារ
គ្រប់គ្រងទីផ្សារ នៃអាហារកែច្នៃ ពួកយើងចង់ បានអាហារពិត!
បែងចែកដីធ្លី ឡើងវិញ។ ធនធាន ធម្មជាតិត្រូវស្ថិត នៅក្នុងដៃរបស់ មនុស្សមិនមែន សាជីវកម្មទេ។
ការពារ និងពង្រីកដែនដី លើកកម្ពស់ ទីផ្សារក្នុងស្រុក
បញ្ឈប់លក្ខខណ្ឌការងារ ដែលកេងប្រវ័ញ្ច និងបង្ក គ្រោះថ្នាក់ ប្រាក់ឈ្នួលទាប និងវិសមភាពយេនឌ័រ។
កសិករ, ជនជាតិដើម ភាគតិច, និងសិទ្ធិកម្មករ
ដីមានសុខភាពល្អ, អាហារមានសុខភាពល្អ, ប្រជាជនមានសុខភាពល្អ។ យើងត្រូវការផ្លាស់ប្តូរទៅ ជាកសិត្របរិស្ថាន!
ប្រជាជនមិនមែន សាជីវកម្ម ជាអត្ថិភាពទេ!
ជីវភាពសមរម្យ សម្រាប់អ្នកធ្វើការក្នុងសេវា ទាំងអស់លើប្រព័ន្ធអាហារ។ បញ្ឈប់ការកេងប្រវ័ញ្ច!
សិទ្ធិស្ត្រី ឥឡូវនេះ!
យើងដឹងថាអ្វីដែលល្អ បំផុតសម្រាប់កូនរបស់ យើង។ ឈប់កុហស កូនចៅរបស់យើងទៅ!



តើអ្នកនិយាយថាវានឹងក្លាយជាពៀងដែលជោគជ័យមែនទេ?
ហាមប្រើថ្នាំសម្លាប់សត្វល្អិត និងដីដែលបំពុលមនុស្ស និងភពផែនដី!
យើងមិនចង់បានសប្បុរសធម៌ទេ
ឈប់ប៉ះពាល់ដីយើង
បញ្ឈប់ការទន្ទ្រានយកដី
បញ្ឈប់អំពើហិង្សាលើស្ត្រី!
ខ្ញុំគិតថាខ្ញុំនឹងទៅដុំវិញព្រះច័ន្ទមួយរយៈ
ប្រព័ន្ធស្បៀងសម្រាប់ប្រជាជន
ការពារសិទ្ធិទទួលបានស្បៀងអាហារ និង អាហារូបត្ថម្ភរបស់យើង!
ការងាររបស់យើងមានតម្លៃ
ប្រព័ន្ធស្បៀងសម្រាប់ប្រជាជន
ឈប់ប៉ះពាល់គ្រាប់ពូជយើង
ឈប់ប៉ះពាល់ទឹកយើង
អីគេហ្នឹ យើងជាគ្រួសារតែមួយ
ចូលរួមជាមួយយើង!
សមភាពយេនឌ័រឥឡូវនេះ!
ចូលរួមជាមួយយើង!
បញ្ឈប់ការពីសអើងពូជសាសន៍

មនុស្សគ្រប់រូបមានតួនាទីក្នុងការពង្រឹងប្រព័ន្ធស្បៀងអាហារក្នុងស្រុក និងគាំទ្រដល់អ្នកដែលផលិតអាហាររបស់យើង។ យើងអាចធ្វើដូច្នេះមិនត្រឹមតែតាមរយៈជម្រើសអាហារបុគ្គលរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏តាមរយៈការតស៊ូមតិជាមួយរដ្ឋាភិបាលរបស់យើង រួមទាំងរដ្ឋាភិបាលក្នុងតំបន់ផងដែរ។ យើងត្រូវតែអំពាវនាវឱ្យពួកគេការពារនូវចន្លោះខ្វះខាតរាល់គោលនយោបាយសាធារណៈ អំពីឥទ្ធិពលរបស់សាជីវកម្មដើម្បីធានាឱ្យមានការចូលរួមប្រកបដោយពេញលេញនៃអ្នកផលិតអាហារខ្នាតតូច និងក្រុមផ្សេងទៀតដែលរងផលប៉ះពាល់ដោយភាពអត់ឃ្លាន និងកង្វះអាហារូបត្ថម្ភ ហើយព្រមទាំងដាក់ចេញនូវគោលនយោបាយ និងវិធានការផ្សេងទៀតដែលគាំទ្រនឹងការការពាប្រព័ន្ធស្បៀងអាហារក្នុងស្រុក ដែលទ្រទ្រង់ដោយធម្មជាតិ រួមចំណែកដល់សុខភាពមនុស្ស និងលើកកម្ពស់យុត្តិធម៌សង្គម។

## **ចូលរួមការឆ្លើយតបស្វ័យភាពរបស់ប្រជាជនចំពោះកិច្ចប្រជុំកំពូលប្រព័ន្ធស្បៀងអាហាររបស់អង្គការសហប្រជាជាតិ!**

https://www.foodsystems4people.org/about-2/

រៀបចំដោយ FIANអន្តរជាតិ

សូមចូលទៅកាន់ FIAN.org ដើម្បីស្វែងយល់បន្ថែម

**អានសេរីសៀវភៅតុក្ក ESCR-Net**

**"អំណាចនៃ ៩៩ភាគរយ ដើម្បីបញ្ឈប់ការចាប់យកសាជីវកម្ម"។**

**ចូលទៅកាន់ ESCR-Net.org**

FIAN INTERNATIONAL

បកប្រែជាភាសាខ្មែរដោយ៖
អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ

Translated by:
SOCIAL ACTION FOR COMMUNITY AND DEVELOPMENT
www.sacd.unitedsisterhood.org